002/19-09-2007-ECCC/TC
E1/59

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 04 / 2012
ម៉ោង (Time/Heure) : 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ០៤ ខែ មេសា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤៧

រៀបចំដោយ: សែ កុលវុឌ្ឍី និង **Roger PHILLIPS**

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក Dale LYSAK, លោក ពេជ្រ សម្បត្តិ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT លោកស្រី ម៉ុច សុវណ្ណារី, លោក Barnabé NEKUIE, លោក វែន ពៅ, លោក ហុង គឹមសួន, លោកស្រី ជេត វណ្ណលី, លោកស្រី Marie GUIRAUD |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក ព្រំ ផល្លា, លោក ស្វ មូស្សេន្ទី, លោក Philippe GOUT |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃ ពុធ ទី ០៤ ខែ មេសា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៥ (៧ ម៉ោង) |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៤០ | បញ្ចប់ម៉ោង៖ ១១.00 (២០ នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៣.៤០ (មួយម៉ោង និង ៤០នាទី) |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១០ (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ៤ ម៉ោង និង ៤០ នាទ |

| **<u>កិច្ចដំណើរការនីតិវិធីផ្សេងៗ៖</u>** | | | |
|---|---|---|---|
| **ប្រភេទបញ្ហា** | **លើកឡើងដោយ** | **ម៉ោងចាប់ផ្តើម** | **ម៉ោងបញ្ចប់** |
| ការបញ្ជាក់របស់អង្គជំនុំជម្រះ ចំពោះសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី | អង្គជំនុំជម្រះ | ៩.០៥ | ៩.១០ |
| សំណើសុំរបស់ ជនជាប់ចោទ នួន ជាក្នុងការឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី | មេធាវីការពារឱ្យ នួន ជា | ៩.១០ | ៩.២០ |
| ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច | មេធាវីការពារឱ្យ នួន ជា | ៩.២០ | ១៦.00 |

| | | | |
|---|---|---|---|
| ការពិភាក្សាអំពីឯកសារដែលអង្គជំនុំជម្រះមិនទាន់កំណត់អំពីយថាភាពនៅក្នុងសំណុំរឿងលេខ០០១ | អង្គជំនុំជម្រះ | ១១.៤៥ | ១២.០០ |
| សំណើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅបន្ទប់សវនាការ | មេធាវីការពារឲ្យ អៀង សារី<br>មេធាវីការពារឲ្យ នួន ជា | ១០.៣៥<br>១២.០០ | ១០.៣៦<br>១២.០០ |
| សំណើសុំបន្ថែមពេលវេលាសម្រាប់តាំងសំណួរទៅសាក្សី | មេធាវីការពារឲ្យ នួន ជា | ១៦.០០ | ១៦.០៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការបញ្ជាក់អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់សាក្សី</u>**

អង្គជំនុំជម្រះបានរំលឹកថា អនុលោមតាមវិធាន ២៨នៃវិធានផ្ទៃក្នុង សាក្សីអាចជំទាស់ទៅនឹងការឆ្លើយ ឬធ្វើសេចក្តីថ្លែងការណ៍ដែលអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងនេះគ្របដណ្តប់លើអង្គហេតុទាំងឡាយដែលមិនទាន់ត្រូវបានវិនិច្ឆ័យសេចក្តីជាស្ថាពរ។ ក្នុងករណីដែលសាក្សីកំពុងធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ សាក្សីអាចជំទាស់ទៅនឹងការឆ្លើយទៅនឹងសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយ ដែលមិនទាន់វិនិច្ឆ័យសេចក្តីក្នុងសំណុំរឿង០០១ ហើយដែលអាចនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដែលអាចនឹងត្រូវចោទប្រកាន់នាពេលអនាគត។ សាក្សីគប្បីនិយាយឲ្យបានច្បាស់ ប្រសិនបើ និងពេលដែលខ្លួនមានបំណងអនុវត្តសិទ្ធិនេះ។

**<u>សំណើសុំរបស់ជនជាប់ចោទ នួន ជា ក្នុងការឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី</u>**

មេធាវីការពារឲ្យ នួន ជា បានថ្លែងថា ជនជាប់ចោទ នួន ជា នឹងមិនចូលរួមដំណើរការសវនាការដោយផ្ទាល់នៅពេលរសៀលនេះទេ និងបានស្នើសុំឲ្យនួន ជា ផ្តល់មតិយោបល់ចំពោះសក្ខីកម្មរបស់ឌុចក្នុងពេលឥឡូវ។ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានចំពោះសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះបដិសេធសំណើសុំនេះដោយសារមិនទាន់ដល់ពេលដែលជនជាប់ចោទត្រូវផ្តល់មតិយោបល់។

**<u>ការតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច</u>**

មេធាវីការពារឲ្យ នួន ជា បានតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច អំពីភាពគួរឲ្យជឿជាក់បានរបស់សាក្សី ទោះបីជាការតាំងសំណួរលើសពីវិសាលភាពនៃសវនាការវគ្គទី១នេះក៏ដោយ។ មេធាវី

ការពារឲ្យ នួន ជា បានថ្លែងទៀតថាគាត់អាចប្រើប្រាស់ឯកសារផ្សេងៗក្នុងការតាំងសំណួរទៅសាក្សីនេះ ដោយមិនចាំបាច់យោងទៅលើបញ្ជីឯកសារជាក់លាក់ ដោយរួមទាំងឯកសារប្រតិចារិកក្នុងសំណុំរឿងលេខ០០១ផងដែរ។ អង្គជំនុំជម្រះបានថ្លែងថា មេធាវីការពារមានសិទ្ធិក្នុងការសួរដេញដោលអំពីភាពអាចជឿជាក់បានរបស់សាក្សីនេះ ប៉ុន្តែឯកសារដែលបានប្រើប្រាស់ក្នុងការដេញដោលត្រូវតែមាននៅក្នុងសំណុំរឿង និងត្រូវជូនដំណឹងឲ្យភាគី ក៏ដូចជាអង្គជំនុំជម្រះបានដឹងជាមុនយ៉ាងតិចរយៈពេល២៤ម៉ោង។ សាក្សីមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយគាត់ក៏មានសិទ្ធិមិនឆ្លើយទៅនឹងអង្គហេតុណាដែលមិនទាន់បានវិនិច្ឆ័យសេចក្តីជាស្ថាពរដែរ ចំណែកឯកសារថ្មីដែលមិនមាននៅក្នុងសំណុំរឿងមិនអនុញ្ញាតិឲ្យធ្វើការដេញដោលនោះទេ។

**ការស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និងនួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំនេះ។

**ការពិភាក្សាអំពីឯកសារដែលអង្គជំនុំជម្រះមិនទាន់កំណត់អំពីយថាភាពនៅក្នុងសំណុំរឿងលេខ០០១**

ដោយយោងទៅលើឯកសារ IS 20.29 អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះមិនទាន់បានកំណត់អំពីយថាភាពនៃឯកសារនេះទេនៅក្នុងសំណុំរឿងលេខ០០១។ សាក្សីត្រូវតែឆ្លើយទៅនឹងសំណួរដែលពាក់ព័ន្ធនឹងឯកសារនេះ ហើយសាក្សីក៏អាចបង្ហាញអំពីការយល់ឃើញរបស់ខ្លួនចំពោះឯកសារនេះផងដែរ។ មេធាវីការពារឲ្យ នួន ជា បានបញ្ជាក់ថា ការកំណត់អំពីយថាភាពនៃឯកសារគឺធ្វើឡើងដោយភាគី មិនមែនសាក្សីនោះទេ។

**សំណើសុំពេលវេលាបន្ថែមសម្រាប់ការតាំងសំណួរទៅសាក្សី**

មេធាវីការពារឲ្យនួន ជា បានស្នើសុំពេលវេលាបន្ថែមមួយម៉ោងសម្រាប់បន្តតាំងសំណួរទៅឌុច។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣)**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/45 | D95 | 00205146-00205155 00205156-00205163 00205164-00205172 | [លិខិតបញ្ជាក់ការជំនូសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ថ្ងៃទី ១៥ កក្កដា ២០០៨ Written Record of Interview of Duch by CIJ on 15-07-2008 Procès verbal d'interrogatoire de Duch par CJI le 15-07-2008 | P | 00205150 | 00205159 | 00205167 |
| E3/1558 | D43/IV-Annex 63 | 00174501-00174543 00224130-00224130 00269783-00269783 | ឧបសម្ព័ន្ធ៦៣: ៥៧៥bbkkh សម្រង់ចម្លើយសារភាពរបស់ ម៉ែន ជុន ហៅ ហ៊ឹង្ស Annex 63: 575bbkkh Colour copy Excerpt of Confession of Men Chun alias Hoeng Annex 63: 575bbkkh l'extrait en copie couleur de la confession de Men Chun alias Hoeng | P | 00174502 | 00224130 | 00269783 |
| E3/1559 | D288/4.11.1 | 00320948-00321033 00316531-00316639 00316640-00316755 | ប្រតិចារិតនៃដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច - ០៩ មេសា ២០០៩ Transcript of Proceedings - "Duch" Trial - 09 April 2009 Transcript of Proceedings - "Duch" Trial - 09 April 2009 | P | 00321001 | 00316602 | |
| E3/454 | D86/6 | 00146657-00146667 00147600-00147608 00149920-00149931 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០២ ១០ ២០០៧ Written Record of Interview of Duch by CIJ on 02-10-2007 Procès verbal d'interrogatoire de Duch par CJI le 02-10-2007 | P | 00146663 | 00147605 | p. 6 |
| E3/1560 | D288/6.52/4.25 | 00320786-00320789 00327325-00327327 00327328-00327331 | ឧបសម្ព័ន្ធ ២៥៖ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៩ Annex 25: Written Record of Interview - 09 June 1999 Annexe 25: Procès-verbal d'interrogatoire - 09 juin 1999 | P | 00320787 | 00377326 | |
| E3/347 | 20.19 | 00160879-00160884, 00002494-00002557, 00160889-00160920 00184996-00185058, 00160885-00160888 00160921-00160974 | បទសម្ភាសន៍តាមខ្សែអាត់ជាមួយ កាំង ហ្គិច អ៊ាវ ហៅ ឌុច អតីតប្រធានសន្តិសុខខ្មែរក្រហម ស-២១ UNHCHR Suspect Statement of KANG Keck Iev alias DUCH UNHCHR Suspect Statement of KANG Keck Iev alias DUCH | P | 00160904 | 00185024 | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/1537 | D43/IV-Annex 75 | 00174754-00174760 00224639-00224639 00271459-00271459 | ឧបសម្ព័ន្ធ ៧៥៖ ៦៤២bbkkh សម្រង់ចម្លើយសារភាពរបស់ ទីវ ម៉ី ហៅ សន្តិភាព<br>Annex 75: 642bbkkh Colour copy Excerpt of Confession of Tiv Mei alias Santepheap<br>Annexe 75: 642bbkkh l'extrait en copie couleur de la confession de Tiv Mei alias Santepheap | P | 00174754 | | |
| E3/1546 | D43/IV-Annex 26 | 00173049-00173056 00753705-00753710, 00224630-00224630 00757862-00757868, 00271450-00271451 | ឧបសម្ព័ន្ធ២៦: 319bbkkh សម្រង់ចម្លើយសារភាពរបស់ ម៉ុក សំអុល ហៅ ហុង<br>Annex 26: 319bbkkh Colour copy Excerpt of Confession of Mok Sam-ol alias Hong [Partial T.] Annexe 26: Aveux de MOK Sam Ol alias HONG à S-21 (annotations des extraits de couleur) | P | 00173049 | | |
| E3/1561 | D43/IV-Annex 74 | 00174736-00174753 00629418-00629418 00280058-00280058 | ឧបសម្ព័ន្ធ៧៤: 636bkkh សម្រង់ចម្លើយសារភាពរបស់ ឡុង មុយ ហៅ ជួន<br>Annexe 74: 636bkkh l'extrait en copie couleur de la confession de Long Muy alias Chuon<br>Annexe 74: 636bkkh l'extrait en copie couleur de la confession de Long Muy alias Chuon | P | 00174736 | 00629418 | 00280058 |
| E3/83 | D225 | 00398154-00398160 00398161-00398167 00398168-00398174 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះ ថ្ងៃទី ២០-១០-២០០៩<br>Written Record of Interview of Duch by CIJ on 20-10-2009<br>Procès verbal d'interrogatoire de Duch par CJI le 20-10-2009 | P | 00398157 | 00398164 | 00398171 |
| E3/1562 | D43/IV-Annex 77 | 00174764-00174774 00223909-00223910 00280059-00280060 | ឧបសម្ព័ន្ធ៧៧៖ 740bbkkh សម្រង់ចម្លើយសារភាពរបស់ ហ៊ាប ស៊ុនហួង ហៅ ភាត<br>Annex 77: 740bbkkh Colour copy Excerpt of Confession of Heap Sun Huong alias Pheat<br>Annexe 77: 740bbkkh l'extrait en copie couleur de la confession de Heap Sun Huong alias Pheat | P | 00174764 | 00223909 | 00280059 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1047 | D108/50/1.5 | 00002455-00002455 00548892-00548892 | លិខិតរបស់ ខៀវ ផ្ញើឱ្យ ឌុច ស្តីពីការប្រើប្រាស់ក្រដាស Annex 5: Describing instructions from SON Sen alias Khieu to KAING Guek Eav alias Duch to save paper while recording confessions, to pay more attention to their contents, to make assessment of the values of the confessions | P | | | |
| E3/449 | D86/11 | 00158835-00158842 00159552-00159559 00158843-00158850 | កំណត់ហេតុសួរចម្លើយ ឌុច ចុះថ្ងៃទី ២១ ០១ ២០០៨ Written Record of Interview of Duch by CIJ on 21-01-2008 Procès verbal d'interrogatoire de Duch par CJI le 21-01-2008 | P | 00158841 | 00159558 | 00158849 |
| E3/1563 | D43/IV-Annex 96 | 00175121-00175187 00224132-00224135 00244529-00244533 | ឧបសម្ព័ន្ធ៩៦: ៨៦៣bbkkh សម្រង់ចម្លើយសារភាពរបស់ ពេជ ផន ហៅ ម៉ៃ ផូ Annex 96: 863bbkkh Colour copy Excerpt of Confession of Pech Phan alias Mey Phau Annexe 96: 863bbkkh l'extrait en copie couleur de la confession de Pech Phan alias Mey Phau | P | 00175121 | 00224132 | 00244529 |
| E3/1564 | D238 | 00403873-00403883 00403884-00403893 00403894-00403903 | កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី 10-11-2009 Writen Record of Interview of Duch by CIJ dated 10-11-2009 Procès verbal d'interrogatoire de Duch par CJI le 10-11-2009 | P | 00403877 | 00403888 | 00403898 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣៥) និង នួន ជា (ម៉ោង ១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ ( លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរនេះមានភ្ជាប់មកជាមួយនឹងកំណត់ហេតុនេះ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំសាក្សី កាំង ហ្គេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២។

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ០៥ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

**សែ កុលទុដ្ឋី** Roger PHILLIPS